**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣*៧

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
លេខ.០០៦........សរណន.សអយ

# សារាចរណែនាំ

## ស្តីពី

## ការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល

ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពតាមមាត្រា ៣ នៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំអនុវត្តដូចតទៅ :

### I- របៀបគណនាប្រាក់សោធនថ្មីរបស់និវត្តជន និងជនពិការបង់សម្បទាវិជ្ជាជីវៈ

និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនកន្លងមក ត្រូវបានកែសំរួលប្រាក់សោធនតាមការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដោយគណនាតាមរូបមន្តដូចខាងក្រោម :

**ប្រាក់សោធនសរុបប្រចាំខែថ្មី-ប្រាក់សោធនសុទ្ធសាធប្រចាំខែចាស់+ ១៥% នៃប្រាក់សោធនសុទ្ធសាធប្រចាំខែចាស់ + ប្រាក់ឧបត្ថម្ភផ្សេងៗ**

- ចំពោះនិវត្តជនដែលមានប្រាក់សោធនសុទ្ធសាធប្រចាំខែទាបជាងប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំ-ប្រាក់របស់សាមីខ្លួន ការគណនាប្រាក់ដំឡើង ១៥ % នៃប្រាក់សោធនសុទ្ធសាធគឺត្រូវយកប្រាក់បៀវត្សមូលដ្ឋានអប្បបរមានោះគុណនឹង១៥ % ។

- ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានប្រាក់សោធនសុទ្ធសាធប្រចាំខែទាបជាង ៩០% នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំប្រាក់របស់សាមីខ្លួន ការគណនាប្រាក់ដំឡើង ១៥% នៃប្រាក់សោធនសុទ្ធសាធគឺត្រូវយក ៩០% នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមានោះគុណនឹង ១៥% ។

**ឧទាហរណ៍ទី ១ :**

និវត្តជនម្នាក់មានតារាងកាំប្រាក់ ឃ១.១= ៥២ ៥០០៛០០ ។ ពេលចូលនិវត្តន៍គាត់មានភាគរយប្រាក់សោធននិវត្តន៍ស្មើនឹង ៨០% នៃបៀវត្សមូលដ្ឋានរបស់គាត់ ។មុនពេលធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល គាត់មានប្រាក់សោធន



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរស័ព្ទ /ទូរសារ: (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

និវត្តន៍សុទ្ធសាធប្រចាំខែចំនួន ៥៧ ៧៥០៖០០ ។ ដូច្នេះការគណនាប្រាក់សោធននិវត្តន៍របស់គាត់គឺៈ

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៥២ ៥០០៖០០ x ៨០% = ៤២ ០០០៖០០
- ប្រាក់បៀវត្សមូលដ្ឋានអប្បបរមានៃតារាងកាំប្រាក់ ឃ១.៦ = ៤២ ៣០០៖០០
- ប្រាក់បន្ថែមអោយស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៣០០៖០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៤២ ៣០០៖០០
- ប្រាក់មង្គ្រប់ = ១៥ ០០០៖០០
- ប្រាក់បន្ថែមអោយស្មើប្រាក់សោធននិវត្តន៍ចាស់ = ៤៥០៖០០
- ប្រាក់ដំឡើង ១៥%នៃប្រាក់សោធននិវត្តន៍សុទ្ធសាធ ៤២ ៣០០៖០០ x ១៥% = ៦ ៣៤៥៖០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធថ្មី ៤២ ៣០០៖០០ + ៦ ៣៤៥៖០០ = ៤៨ ៦៤៥៖០០

ដូច្នេះប្រាក់សោធននិវត្តន៍ប្រចាំខែដែលត្រូវទទួល=៤៨ ៦៤៥៛+១៥ ០០០៛+៤៥០៛ = ៦៤ ០៩៥៖០០

**ឧទាហរណ៍ទី ២:**

ជនបាត់បង់សម្បទាវិជ្ជាជីវៈម្នាក់មានតារាងកាំប្រាក់ គ៣-១៤ = ៤៥ ០០០៖០០ ។ ពេលចូលបាត់បង់សម្បទាវិជ្ជាជីវៈ គាត់មានភាគរយប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ស្មើនឹង ៦៥% នៃបៀវត្សមូលដ្ឋានរបស់គាត់ ។ ដូច្នេះការគណនាប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈរបស់គាត់គឺៈ

- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធប្រចាំខែ ៤៥ ០០០៖០០ x ៦៥% = ២៩ ២៥០៖០០
- ៩០%នៃប្រាក់បៀវត្សមូលដ្ឋានអប្បបរមា គ៣.១៤ =៤៥ ០០០៖០០ x ៩០% = ៤០ ៥០០៖០០
- ប្រាក់បន្ថែមអោយស្មើនឹង ៩០%នៃបៀវត្សមូលដ្ឋានអប្បបរមា = ១១ ២៥០៖០០
- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធប្រចាំខែស្មើនឹង ៩០%នៃបៀវត្សមូលដ្ឋានអប្បបរមា = ៤០ ៥០០៖០០
- ប្រាក់ដំឡើង ១៥%នៃប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធ ៤០ ៥០០៖០០ x ១៥% = ៦ ០៧៥៖០០

ដូច្នេះប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែដែលត្រូវទទួល

៤០ ៥០០៖០០ + ៦ ០៧៥៖០០ = ៤៦ ៥៧៥៖០០

ការបូកបន្ថែម ១៥ % នៃប្រាក់សោធនសុទ្ធសាធរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវអនុវត្តចាប់ពីខែ មករា ឆ្នាំ ២០០៥ នេះតទៅ ។

## II-របៀបគណនាប្រាក់សោធនរបស់មន្ត្រីរាជការចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរសព្ទ /ទូរសារៈ (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

ក- ប្រាក់សោធនរបស់មន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ត្រូវបានបូកបន្ថែម១៥%នៃប្រាក់សោធនសុទ្ធសាធប្រចាំខែរបស់សាមីជន ដោយគណនាតាមរូបមន្តដូចខាងក្រោម :

**ប្រាក់សោធនសរុបប្រចាំខែ = ប្រាក់សោធនសុទ្ធសាធប្រចាំខែ + ១៥% នៃប្រាក់សោធនសុទ្ធសាធប្រចាំខែ + ប្រាក់ឧបត្ថម្ភផ្សេងៗ**

ប្រាក់សោធនសុទ្ធសាធប្រចាំខែត្រូវគណនាលើប្រាក់បៀវត្សមូលដ្ឋានចាស់ ។

ខ-ប្រាក់សោធនរបស់មន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៥ តទៅ ត្រូវគណនាតាមរូបមន្តដូចខាងក្រោម :

**ប្រាក់សោធនសរុបប្រចាំខែ = ប្រាក់សោធនសុទ្ធសាធប្រចាំខែ + ប្រាក់ឧបត្ថម្ភផ្សេងៗ**

ប្រាក់សោធនសុទ្ធសាធប្រចាំខែត្រូវគណនាលើប្រាក់បៀវត្សមូលដ្ឋានថ្មី ។

**ឧទាហរណ៍ ទី ៣**

មន្ត្រីម្នាក់មានតារាងកាំប្រាក់ ឃ១-១= ៦០ ៣៧៥៛០០ ត្រូវចូលនិវត្តន៍នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៥ ។ពេលចូលនិវត្តន៍គាត់មានភាគរយសោធននិវត្តន៍ស្មើនឹង ៨០% ។ មុនពេលធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល បើគណនាប្រាក់សោធននិវត្តន៍សុទ្ធសាធរបស់គាត់គឺមានចំនួន ៦៤ ០៩៥៛០០ ។ ដូច្នេះការគណនាប្រាក់សោធននិវត្តន៍សុទ្ធសាធរបស់គាត់គឺ:

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៦០ ៣៧៥៛០០ x ៨០% = ៤៨ ៣០០៛០០
- ប្រាក់បៀវត្សមូលដ្ឋានអប្បបរមា ឃ១-៦ = ៤៨ ៦៤៥៛០០
- ប្រាក់បន្ថែមអោយស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៣៤៥៛០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែស្មើនឹងបៀវត្សមូលដ្ឋានអប្បបរមា = ៤៨ ៦៤៥៛០០
- ប្រាក់បង្រ្គប់ = ១៥ ០០០៛០០
- ប្រាក់បន្ថែមអោយស្មើប្រាក់សោធននិវត្តន៍ចាស់ = ៤៥០៛០០

ដូច្នេះប្រាក់សោធននិវត្តន៍ប្រចាំខែដែលត្រូវទទួល=៤៨ ៦៤៥៛ + ១៥ ០០០៛ + ៤៥០៛ = ៦៤ ០៩៥៛០០

គ-ទម្រង់បែបបទស្នើសុំ ប្រាក់សោធនថ្មី

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង ត្រូវធ្វើលិខិតស្នើសុំកែប្រែប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយភ្ជាប់មកជាមួយនូវ:

- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ប្រចាំខែចុងក្រោយ ចំនួន ០១ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈថ្មី ចំនួន ០១ ច្បាប់

បន្ទាប់ពីបានទទួលការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា លើតារាង



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ,ទូរស័ព្ទ /ទូរសារ: (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726086

ប្រាក់សោធនថ្មីមក ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង មានសិទ្ធិចុះហត្ថលេខានៅលើទំព័រ " ប្តូរប្រាក់បៀវត្សគិតពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ " របស់សៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

សារាចរណែនាំលេខ ០០៣ សរណន.សអយ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកែប្រែឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ត្រូវចាត់ទុកជានិរាករណ៍ ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- គ្រប់សាលា ខេត្ត - ក្រុង
  " ដើម្បីជូនជ្រាបជាពត៌មាន "
- គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- គ្រប់មន្ទីរ ស អ យ ខេត្ត - ក្រុង
  " ដើម្បីសហការអនុវត្ត "
- ឯកសារ - កាលប្បវត្តិ